ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍

## កិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់

## ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៤ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

### ១-គោលបំណង

គោលបំណងនៃកិច្ចប្រជុំមាន ការពិនិត្យមើល និងពិភាក្សាលើផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់។

តាមរយៈនៃកិច្ចប្រជុំ សមាជិកក្រុមការងារទាំងអស់រំពឹងថា នឹងទទួលបាននូវផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

### ២-កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន

កាលបរិច្ឆេទ : ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៤

ទីកន្លែង : នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

វត្តមាន : អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ FHI360, MHC, KHEMARA, MEC and SIT

### ៣-វិធីសាស្ត្រ

ពិភាក្សារួម

### ៤-លទ្ធផល

កាលពីថ្ងៃអង្គារ ទី៤ ខែកក្កដា ឆ្នាំ២០១៤ វេលាម៉ោង៨:៣០នាទីព្រឹក នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ បានរៀបចំនូវកិច្ចប្រជុំប្រចាំខែរបស់ខ្លួនក្រោមកិច្ចដឹកនាំប្រជុំដោយ ឯកឧត្តម តែង គន្ធី អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់។ ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រធានអង្គប្រជុំ បានថ្លែងអំណរគុណដល់សមាជិកក្រុមការងារលេខាធិការដែលបានចូលរួមប្រជុំនាពេលនេះ និងបានពិនិត្យពិភាក្សាលំអិតលើយុទ្ធសាស្ត្រនីមួយៗនៃផែនការសកម្មភាពរបស់ក្រុមការងារបុរសស្រឡាញ់បុរស និងស្រីស្រស់ ដោយសំរេចលទ្ធផលដូចខាងក្រោម៖

១. តាមរយៈនៃកិច្ចប្រជុំ ក្រុមការងារលេខាធិការដ្ឋានសំរេចថា រាល់សកម្មភាពដែលមានក្នុងផែនការប្រចាំឆ្នាំរបស់ក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ ស្នើរសូមផែនការសកម្មភាពដែលអនុវត្តជាប្រចាំ និងផែនការចុះអភិបាលកិច្ច ពីអង្គការដៃគូទាំងអស់។

២. តាមរយៈនៃកិច្ចប្រជុំ ក្រុមការងារលេខាធិការដ្ឋានសង្កេតឃើញថា ក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០១៤ មានសកម្មភាពខ្លះហាក់ដូចជាជាន់គ្នា សកម្មភាពខ្លះទៀតមិនមានដំណើរការ ដែលក្រុមការងារសំរេច ដាក់បញ្ចូលគ្នា ឬដកចេញ(សកម្មភាពទីមួយក្នុងយុទ្ធសាស្រ្តទីមួយ ស្រដៀងគ្នាជាមួយសកម្មភាពទីបី និងទីបួន ក្នុងយុទ្ធសាស្រ្តទីពីរ)។ ជាមួយគ្នានេះ មានបញ្ចូលសកម្មភាពខ្លះទៀតដូចជា កែលំអរប្រព័ន្ធព័ត៌មានក្នុងក្រុមការងារពិសេស គេហទំព័ររបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់។

៣. រាល់ការអញ្ជើញ ឬចូលរួមសកម្មភាពផ្សេងៗដូចជា ការចុះអភិបាលកិច្ច ការចូលរួមប្រជុំ ការចូលរួមវគ្គបណ្តុះបណ្តាលនានា របស់សមាជិកក្រុមការងារ ត្រូវផ្ញើរមកមុននូវផែនការសកម្មភាពរបស់ខ្លួនមកក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ ។

៤. ស្នើសូមសមាជិកក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ ជារៀងរាល់ខែ ត្រូវសាកសួរព័ត៌មានពីគ្រប់អង្គការដៃគូ ក្នុងការចុះអភិបាលកិច្ចនៅតាមតំបន់គោលដៅនានា។

៥. ចំពោះអង្គការ MEC ដែលជួបបញ្ហាថវិការយៈពេលជាងប្រាំមួយខែមកហើយនោះ ប្រធានអង្គប្រជុំបានជូនដំណឹងដល់សមាជិកក្រុមការងារក៏ដូចជាអង្គការMECថា ឯកឧត្តមបានជំរាបជូនឯកឧត្តមទេសរដ្ឋមន្រ្តី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងបានសរសេរជាលិខិតផ្លូវការទៅបីស្ថាប័នផ្សេងទៀត ដើម្បីជួយអន្តរាគមន៍ ពីព្រោះអង្គការ MEC ជាអង្គការមួយផ្តល់សេវាសុខភាពដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ដោយមិនយកថវិកា ដែលបានរួមចំណែកក្នុងការឆ្លើយតបនឹងគោលការណ៍សូន្យបីរបស់រាជរដ្ឋាភិបាលកម្ពុជា។

៦. ចំពោះបណ្តាញចតុមុខ ជាបណ្តាញថ្នាក់ជាតិ និងមានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល បុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រចាំប្រទេសកម្ពុជានោះ ដែលបច្ចុប្បន្ននេះមានការគាំទ្រថវិកាពីអង្គការខាណាក្រុមការងារលេខាធិការសំរេចធ្វើការទំនាក់ទំនងជាមួយខាណា ចំពោះការអនុវត្តន៍សកម្មភាពរបស់បណ្តាញ។

៧. ចំពោះការរៀបចំវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយស្តីពីបញ្ហាមេរោគអេដស៍ ជំងឺអេដស៍ និងស្រឡាញ់បុរស និងស្រីស្រស់ និងការវាយតំលៃលើអត្ថបទសាព័ត៌មាន ដើម្បីផ្តល់រង្វាន់ដល់អ្នកសរសេរអត្ថបទ ដែលមានអត្ថន័យ ក្នុងការកាត់បន្ថយការរើសអើង និង ការផ្តល់ចំណេះដឹងជាព័ត៌មានពិតប្រាកដនោះ យើងនឹងពិភាក្សាជាមួយអង្គការខាណា និងUNESCO ដែលមានថវិកាសំរាប់ដំណើរការ។

## ៥-ការងារដែលត្រូវធ្វើបន្ត

១.រៀបចំកិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់នៅខែក្រោយឆ្នាំ២០១៤ នារាជធានីភ្នំពេញ

២. យើងនឹងពិភាក្សាជាមួយខាណា និងUNESCO ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយស្តីពីបញ្ហាមេរោគអេដស៍ ជំងឺអេដស៍ និងស្រឡាញ់បុរស និងស្រីស្រស់ និងការវាយតំលៃលើអត្ថបទសាព័ត៌មាន ដើម្បីផ្តល់ជារង្វាន់លើកទឹកចិត្តដល់អ្នកសរសេរអត្ថបទ ដែលមានអត្ថន័យក្នុងការកាត់បន្ថយការរើសអើង និងការផ្តល់ចំណេះដឹងជាព័ត៌មានពិតប្រាកដ។

៣. ក្រុមការងារលេខាធិការដ្ឋាន នឹងធ្វើអភិបាលកិច្ចការងារនៅតាមបណ្តារខេត្តដែលមានអង្គការរកំពង់ធ្វើសកម្មភាពលើក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

៤. ក្រុមការងារលេខាធិការដ្ឋាននឹងរៀបចំដាក់បញ្ចូនរាល់ឯកសារសកម្មភាពដែលបានអនុវត្តនានាទៅក្នុងគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ភ្នំពេញ ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៨

អ្នកធ្វើរបាយការណ៍

អ៊ឹង សុវណ្ណៈ

បានឃើញ និងពិនិត្យត្រឹមត្រូវ

ប្រធាននាយកដ្ឋាន

បានឃើញ និងឯកភាព

អគ្គលេខាធិការ